II. ទីស្តីការ គណៈរដ្ឋមន្ត្រី

១- អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ២១ អនក្រ ស្តីពីការ បែងចែកខ្ទង់ចំណាយ មិនបានគ្រោងទុក

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើអោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ ស្តីពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៤
- **យោងតាមសំណើរបស់រដ្ឋមន្ត្រី *ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ***

សំរេច

មាត្រា ១ : ផ្តល់ឥណទានបន្ថែមដោយផ្ទេរពីជំពូក ៤១ ‹‹ ចំណាយមិនបានគ្រោងទុក ›› នៃថវិការដ្ឋជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីផ្នែកទី ១ ជំពូក ៥០ ‹‹ ឥណទានសាងសង់ ›› ចំនួន ៦២០.៦២០.០០០ រៀល

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា និងត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និងត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែឧសភា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ២២ អនក្រ ស្តីពីការបង្កើត គណៈបញ្ជាការ ឯកភាពខេត្ត ក្រុង ស្រុក ខ័ណ្ឌ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម **សីហនុ វរ្ម័ន**

សំរេច

មាត្រា ១ : ផ្តល់ឥណទានបន្ថែមដោយផ្ទេរពីជំពូក ៤១ ‹‹ ចំណាយមិនបានគ្រោងទុក ›› នៃថវិការដ្ឋជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីផ្នែកទី ១ ជំពូក ៥០ ‹‹ ឥណទានសាងសង់ ›› ចំនួន ៦២០.៦២០.០០០ រៀល

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែឧសភា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ២២ អនក្រ ស្តីពីការបង្កើត គណៈបញ្ជាការ ឯកភាពខេត្ត ក្រុង ស្រុក ខណ្ឌ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម **សីហនុ វរ្ម័ន**

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា ។

តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានបង្កើត គណៈបញ្ជាការឯកភាពនៅថ្នាក់ ខេត្ត ក្រុង និង ថ្នាក់ស្រុក ខ័ណ្ឌ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

សមាសភាពគណៈបញ្ជាការឯកភាពមាន :

ក- គណៈបញ្ជាការឯកភាព ខេត្ត ក្រុង :

១- អភិបាលខេត្ត ក្រុង	ជាប្រធាន
២- អភិបាលរងទី ១	ជាអនុប្រធាន
៣- មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង	ជាអនុប្រធាន
៤- ស្នងការនគរបាលខេត្ត ក្រុង	ជាសមាជិកអចិន្ត្រៃយ៍
៥- ប្រធានមន្ទីរ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្ត ក្រុង	ជាសមាជិក
៦- អភិបាលស្រុក ខ័ណ្ឌ	ជាសមាជិក

ខ- គណៈបញ្ជាការឯកភាព ស្រុក ខ័ណ្ឌ :

១- អភិបាល ស្រុក ខ័ណ្ឌ	ជាប្រធាន
២- អភិបាលរង	ជាអនុប្រធាន
៣- មេបញ្ជាការផ្នែកប្រតិបត្តិការសឹករង ស្រុក ខ័ណ្ឌ	ជាអនុប្រធាន
៤- អធិការនគរបាល ស្រុក ខ័ណ្ឌ	ជាសមាជិកអចិន្ត្រៃយ៍

៥- ប្រធានការិយាល័យ ផែនការ និង ហិរញ្ញវត្ថុ ស្រុក ខណ្ឌ ជាសមាជិក
៦- ប្រធាន ឃុំ សង្កាត់ ជាសមាជិក

មាត្រា ២ : គណៈបញ្ជាការឯកភាព ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចដូចតទៅ :

១- សំរបសំរួល និង ចាត់ចែងរាល់ការងារដើម្បីឆ្លើយតបសំណូមពរចាំបាច់នៃភារកិច្ចយោធាសន្តិសុខ នៅមូលដ្ឋាន ។

២- តាមដានក្តាប់ជាប់សភាពការណ៍ ឧបាយកលបែបផែនសកម្មភាព របស់ក្រុមខ្មាំង ដែលមានផែនការ ឬសកម្មភាពបំផ្លិចបំផ្លាញមូលដ្ឋាន ។

៣- មានវិធានការបោសសំអាតក្រុមឡោមភូមិសាស្ត្រ តស៊ូទប់ស្កាត់ពួកលបលួចជ្រៀតចូល ភូមិ ឃុំ បង្កអំពើវិទ្ធង្សនា ធ្វើភេរវកម្ម បង្កអសន្តិសុខ បង្ក្រាបទាន់ពេលសកម្មភាពឆក់ប្លន់ កាប់សំលាប់ ចាប់មនុស្សជំរិតយក ប្រាក់ របស់ពួកក្រុមខ្មាំង សំដៅការពារអោយបានសុវត្ថិភាពមូលដ្ឋាន ការពារផ្លូវដែក ផ្លូវគមនាគមន៍ជើងគោក ជើងទឹក ការពារសមិទ្ធិផល របស់សង្គមជាតិក្នុងក្របខ័ណ្ឌ ភូមិសាស្ត្រ ទទួលខុសត្រូវរបស់ខ្លួន ។

៤- មានវិធានការកសាង ពង្រឹងមូលដ្ឋានលើគ្រប់ផ្នែក ពិសេសពង្រឹងផ្លូវរដ្ឋអំណាច ភូមិ ឃុំ ពង្រឹង កំលាំងនគរបាលប៉ុស្តិ៍រដ្ឋបាល និង កងជីវពលនៅមូលដ្ឋាន ។

៥- គួបផ្សំ សកម្មភាពរបស់គណៈកម្មការចំរុះ បង្ការបង្ក្រាបចោរប្លន់ប្រដាប់អាវុធ ដើម្បីបំផុសចលនា ទូលំទូលាយក្នុងប្រជារាស្ត្រ សំដៅពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សុវត្ថិភាពសង្គមនៅមូលដ្ឋាន ។

មាត្រា ៣ : គណៈបញ្ជាការឯកភាព ខេត្ត ក្រុង ស្រុក ខណ្ឌ មានសិទ្ធិដូចតទៅ :

- ចាត់ចែង និង បញ្ជាការកំលាំងក្នុងក្របខ័ណ្ឌភូមិសាស្ត្រដែលខ្លួនទទួលខុសត្រូវក្នុងកិច្ចការ យោធា សន្តិសុខ ដូចមានចែងក្នុងមាត្រា ២ ។
- សហការរវាង ខេត្ត និង ខេត្ត ស្រុក និង ស្រុក ដែលមានភូមិសាស្ត្រជាប់គ្នា ដើម្បីអនុវត្តផែនការរួម ពេលចាំបាច់ ។

- បំផុសអោយស្ថាប័នផ្សេងៗ ក្នុងខេត្ត ក្រុង ចូលរួមយុទ្ធនាការ ឬ វគ្គសកម្មភាពពេលមានសំណូមពរចាំបាច់ ។
- គណៈបញ្ជាការឯកភាពថ្នាក់ខេត្ត ក្រុង មានសិទ្ធបញ្ជា និង ត្រួតពិនិត្យគណៈបញ្ជាការឯកភាពថ្នាក់ស្រុកខណ្ឌ ។
- ធ្វើរបាយការណ៍ជាប្រចាំពីសកម្មភាពរបស់ខ្លួនមកថ្នាក់លើ ។

មាត្រា ៤ : សមាជិកគណៈបញ្ជាការគ្រប់រូបចូលរួមធ្វើការងារ តាមការអញ្ជើញ និង ណែនាំរបស់ប្រធាន គណៈបញ្ជាការឯកភាព និង ទទួលខុសត្រូវចំពោះថ្នាក់លើរបស់ខ្លួន ។

មាត្រា ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អភិបាលខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធិភាពខ្ពស់បំផុត ។

មាត្រា ៦ : អនុក្រឹត្យនេះមានអនុភាព គតិយុត្តិចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	តំណាងនាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ស ខេង**

* * *